ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣✵៤

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ០០៨ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ ០៧ ឆ្នាំ ២០០៨

# សេចក្តីណែនាំ
## ស្តីពី
## ការកំណត់ប្រាក់ឧបត្ថម្ភលើកដំបូង និងប្រាក់សោធន ជូនមន្ត្រីរាជការមានក្របខ័ណ្ឌមុខងារសាធារណៈ ទទួលមុខតំណែងនយោបាយ ដែលត្រូវចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ

-អនុវត្តតាមអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។

-ស្មារតីនៃអង្គប្រជុំអន្តរក្រសួង កាលពីថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៨ នៅក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមធ្វើការណែនាំដល់គ្រប់ក្រសួង ស្ថាប័ន ក្នុងការដាក់មន្ត្រីរាជការដែលមានក្របខ័ណ្ឌមុខងារសាធារណៈ ទទួលមុខតំណែងនយោបាយ ឱ្យចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវបានរៀបចំប្រាក់ឧបត្ថម្ភ និងប្រាក់សោធន ដូចខាងក្រោមនេះ:

១-មន្ត្រីរាជការដែលមានក្របខ័ណ្ឌមុខងារសាធារណៈ ទទួលមុខតំណែងនយោបាយ ពេលចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវគណនាប្រាក់ឧបត្ថម្ភលើកដំបូង ដោយយកបៀវត្សសរុបប្រចាំខែចុងក្រោយចំនួន ០៨ខែ ចំពោះនិវត្តជន និង ០៧ខែ ចំពោះជនបាត់បង់សម្បទាវិជ្ជាជីវៈ។

២-ការគណនាប្រាក់សោធនត្រូវគិតតាមកាំប្រាក់បៀវត្សជាក់ស្តែងចុងក្រោយ នៃព្រះរាជក្រឹត្យ។

ទទួលបានសេចក្តីណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តតាមខ្លឹមសារខាងលើដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចំលងជូន:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- -ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- -គ្រប់ក្រសួង/ស្ថាប័ន
- -គ្រប់សាលាខេត្ត/ក្រុង
- - គ្រប់មន្ទីរ ស.អ.យ ខេត្ត/ក្រុង
- -ឯកសារ-កាលប្បវត្តិ